ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
# រដ្ឋមន្ត្រីការបរទេសកម្ពុជា និងម៉ាឡេស៊ី ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆបោក

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បាន ជួបសន្ទនាតាមទូរស័ព្ទជាមួយ **ឯកឧត្តម ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា** (Dato' Sri Saifuddin Abdullah) រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី ដែលបានមកបំពេញទស្សនកិច្ចការងាររយៈពេលខ្លីនៅ រាជធានីភ្នំពេញ នាថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២២ នេះ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងសមភាគីម៉ាឡេស៊ី បានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការរវាង ប្រទេសទាំងពីរលើកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្ម ឆបោក។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស **ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា** បានសម្តែងនូវអំណរគុណ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ ដែលបានផ្តល់ «ជំនួយជាច្រើន» និងបានបំពេញ «ការងារដ៏ល្អ» ក្នុងការជួយសង្គ្រោះជនរងគ្រោះ។ ឯកឧត្តមក៏បានគូសបញ្ជាក់ផងដែរថា មានជនជាតិ ម៉ាឡេស៊ីជាច្រើននាក់ដែលចូលមកកម្ពុជា ដើម្បីធ្វើជំនួញ និងធ្វើការយ៉ាងជោគជ័យ ហើយមានតែ មួយចំនួនតូចប៉ុណ្ណោះដែលរងគ្រោះដោយសារការបោកប្រាស់ការងារ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីការបរទេស **ដាតុ ស្រ៊ី សៃហ្វូឌីន អាប់ឌុលឡា** ថា ឧក្រិដ្ឋកម្មទាំងនេះកើតឡើងនៅគ្រប់ប្រទេស មិនថាជាប្រទេសតូច ឬធំ នោះទេ ហើយយើងទាំងអស់គ្នាត្រូវតែប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ ដោយគូសបញ្ជាក់ថា មធ្យោបាយដ៏ល្អបំផុតដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវរួមដៃគ្នា និងមានកិច្ចសហប្រតិបត្តិការល្អ រវាងប្រទេសទាំងពីរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជានាចំពោះសមភាគីរបស់ឯកឧត្តម អំពីការ ត្រៀមខ្លួនរួចជាស្រេចរបស់កម្ពុជា ក្នុងការធ្វើការជាមួយស្ថានទូតម៉ាឡេស៊ីនៅភ្នំពេញ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មទាំងនេះ៕ ✎.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០២២

**ជុំ សុន្ទរី**

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh